# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៩៖
## វិធីសាស្ត្រសង្ខេប៖

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ គណនាបញ្ចូលគ្នានូវទិន្នន័យពីប្រភពផ្សេងៗគ្នាដែលបង្ហាញពីការយល់ឃើញរបស់ធុរជន និងអ្នកជំនាញក្នុងប្រទេសនីមួយៗទៅលើកម្រិតនៃអំពើពុករលួយនៅក្នុងវិស័យសាធារណៈ។

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយនេះត្រូវបានគណនាតាមជំហានដូចខាងក្រោម៖

1. **ការជ្រើសរើសប្រភពទិន្នន័យ៖** ប្រភពទិន្នន័យនីមួយៗដែលត្រូវបានយកមកប្រើប្រាស់ដើម្បីគណនាសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយនេះ ត្រូវតែបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖
   - ធ្វើការវាយតម្លៃកម្រិតនៃការយល់ឃើញពាក់ព័ន្ធនឹងអំពើពុករលួយនៅក្នុងវិស័យសាធារណៈជាតួលេខបាន
   - ផ្អែកលើវិធីសាស្ត្រស្រាវជ្រាវដែលយកជាការណ៍ និងអាចទុកចិត្តបាន ហើយធ្វើការដាក់ពិន្ទុ និងចំណាត់ថ្នាក់ប្រទេសនានានៅលើមាត្រដ្ឋានតែមួយ
   - ត្រូវបានសិក្សាស្រាវជ្រាវដោយស្ថាប័នដែលមានកិត្តិនាម
   - មានគម្លាតពិន្ទុដែលគ្រប់គ្រាន់ក្នុងការវែកញែកវាងប្រទេសនីមួយៗ
   - ចាត់ចំណាត់ថ្នាក់ដល់ច្រើនប្រទេស
   - ចំណាត់ថ្នាក់នេះត្រូវបានផ្តល់ឱ្យដោយអ្នកជំនាញប្រចាំប្រទេស ឬធុរជន
   - ស្ថាប័ននោះធ្វើការវាយតម្លៃឡើងវិញយ៉ាងហោចណាស់រៀងរាល់ពីរឆ្នាំម្តង

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៩ ត្រូវបានគណនាដោយផ្អែកលើប្រភពទិន្នន័យផ្សេងៗគ្នាចំនួន ១៣ មកពីស្ថាប័នផ្សេងៗគ្នាចំនួន ១២ ដែលឆ្លុះបញ្ចាំងនូវការយល់ឃើញពីអំពើពុករលួយនៅក្នុងរយៈពេលពីរឆ្នាំកន្លងមក។ ប្រភពទិន្នន័យទាំងនោះមានពិពណ៌នាបន្ថែមនៅក្នុងសេចក្តីពណ៌នាលម្អិតរបស់ឯកសារយោង។

2. **កំណត់ស្តង់ដាពិន្ទុទៅលើទិន្នន័យដើម** ទៅជាមាត្រដ្ឋានពិន្ទុ0-១០០ ដែលពិន្ទុ0 ស្មើនឹងកម្រិតខ្ពស់បំផុតនៃការយល់ឃើញពីអំពើពុករលួយ ហើយពិន្ទុ១០០ ស្មើនឹងកម្រិតស្អាតស្អំបំផុតនៃការយល់ឃើញពីអំពើពុករលួយ។ វិធីកំណត់ស្តង់ដាពិន្ទុនេះធ្វើឡើងដោយការដកវាងពិន្ទុរបស់ប្រទេសនីមួយៗ និងមធ្យមនៃប្រភពទិន្នន័យនីមួយៗក្នុងឆ្នាំមូលដ្ឋាន រួចចែកនិងគម្លាតគំរូនៃប្រភពទិន្នន័យនោះនៅក្នុងឆ្នាំមូលដ្ឋាននោះ។ ការដក និងការចែកដោយប្រើប៉ារ៉ាម៉ែត្រពីឆ្នាំមូលដ្ឋាននេះ ដើម្បីធានាថាពិន្ទុសន្ទស្សន៍CPI អាចប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំបាន ចាប់តាំងពីឆ្នាំ២០១២មក។ បន្ទាប់ពីឆ្លងដំណាក់កាលនេះ ពិន្ទុស្តង់ដាត្រូវបានបំប្លែងទៅជាមាត្រដ្ឋានពិន្ទុរបស់សន្ទស្សន៍CPI ដោយធ្វើការគុណជាមួយគម្លាតគំរូរបស់សន្ទស្សន៍CPI ក្នុងឆ្នាំ២០១២ (ស្មើ២០) ហើយបូកនិងមធ្យមនៃសន្ទស្សន៍CPI ក្នុងឆ្នាំ២០១២ (ស្មើ៤៥) ដើម្បីឱ្យសំណុំទិន្នន័យមានខ្នាត0-១០០ដូចគ្នានឹងមាត្រដ្ឋានពិន្ទុសន្ទស្សន៍CPIដែរ។

3. **ការគណនាពិន្ទុមធ្យម៖** ប្រទេស ឬដែនដីមួយដែលនឹងត្រូវបញ្ចូលក្នុងសន្ទស្សន៍CPI គឺត្រូវមានប្រភពទិន្នន័យយ៉ាងហោចណាស់ចំនួន៣ដែលវាយតម្លៃប្រទេសនោះ។ បន្ទាប់មក ពិន្ទុនៃសន្ទស្សន៍CPIរបស់ប្រទេសនោះត្រូវបានគណនាតាមរូបមន្តមធ្យមភាគនៃពិន្ទុស្តង់ដាទាំងអស់ដែលមានសម្រាប់ប្រទេសនោះ។ ពិន្ទុទាំងអស់ត្រូវបានបង្គត់ទៅជាចំនួនគត់។
4. **ការរាយការណ៍ពីភាពមិនច្បាស់លាស់៖** ពិន្ទុសន្ទស្សន៍CPI ត្រូវបានភ្ជាប់មកជាមួយកម្រិតលម្អៀង និងចន្លោះជឿជាក់ ដែលឆ្លុះបញ្ចាំងពីបម្រែបម្រួលនៅក្នុងពិន្ទុរបស់ប្រភពទិន្នន័យនីមួយៗដែលមានសម្រាប់ប្រទេស ឬដែនដីនោះ។